**ឯកសារ៖ JIAAA**

**ដំណោះស្រាយក្នុងការបញ្ជាក់ថាសាលារៀនក្រុង Lynn ជាទីកន្លែងមានសុវត្ថិភាពនិងមេត្រីភាពសម្រាប់សិស្សគ្រប់រូប**

ដោយហេតុថា បេសកកម្មរបស់ Lynn Public Schools (“LPS”) គឺថែរក្សាសហគមន៍សាលារៀនពហុវប្បធម៌ដែលឧទ្ទិសចំពោះការសម្រេចឲ្យបាននូវសក្តានុពលបញ្ញាញាណ រូបកាយ សង្គម និងអារម្មណ៍ពេញលេញរបស់សិស្ស។

LPS ប្តេជ្ញាផ្តល់ជូននូវបរិស្ថានអប់រំប្រកបដោយសុវត្ថិភាព និងមេត្រីភាពដើម្បីបង្កើនស្នាដៃនិងសិទ្ធិឱកាសសម្រាប់សិស្សគ្រប់គ្នាដោយមិនគិតពីស្ថានភាពអន្តោប្រវេសន៍ ប្រភពជាតិសាសន៍ ជនជាតិ ពូជសាសន៍ សាសនា ភេទ និងអត្តសញ្ញាណភេទ ស្ថានភាពសង្គមសេដ្ឋកិច្ច ស្ថានភាពពិការភាព ឬជំនឿ ឡើយ។

ដោយហេតុថា ទីក្រុងមានភាពសម្បូរណ៍បែបនិងរឹងមាំដោយសារមរតកវប្បធម៌ចម្រុះ ប្រជាជនពហុជាតិសាសន៍ និងឥរិយាបថប្រកបដោយមេត្រីភាពចំពោះអ្នកចំណូលថ្មី។

ដោយហេតុថា ការអប់រំដើរតួនាទីសំខាន់នៅក្នុងការលើកតម្កើងភាពអត់ធ្មត់ និងការរួបរួមគ្នា នៅក្នុងសង្គមជាតិរបស់យើង។

ដោយហេតុថា United States Constitution (រដ្ឋធម្មនុញ្ញរបស់សហរដ្ឋអាមេរិក) ហាមប្រាមដល់រដ្ឋទាំងឡាយមិនឲ្យបដិសេធការអប់រំបឋមសិក្សានិងមធ្យមសិក្សាសាធារណៈដល់កុមារដោយផ្អែកលើស្ថានភាពអន្តោប្រវេសន៍របស់ពួកគេឡើយ។

ដោយហេតុថា Civil Rights Act (ច្បាប់សិទ្ធិពលរដ្ឋស៊ីវិល) ឆ្នាំ 1964 ហាមប្រាមមិនឲ្យសាលារៀនបឋមសិក្សានិងមធ្យមសិក្សាសាធារណៈ (ចំណងជើង IV) និងអ្នកទទួលជំនួយហិរញ្ញវត្ថុសហព័ន្ធ រើសអើងប្រឆាំងនឹងពូជសាសន៍ ពណ៌សម្បុរ ឬប្រភពជាតិសាសន៍ និងចំណោមកត្តាផ្សេងៗទៀត ឡើយ។

ដោយហេតុថា Family Educational Rights and Privacy Act (“FERPA”) (ច្បាប់ស្តីពីសិទ្ធិអប់រំគ្រួសារនិងឯកជនភាព) ឆ្នាំ 1974 និងច្បាប់រដ្ឋ Massachusetts បានហាមប្រាមជាទូទៅដល់មណ្ឌលសាលារៀននិងបុគ្គលិករបស់ខ្លួនមិនឲ្យលាតត្រដាងព័ត៌មានពីសៀវភៅសិក្ខាគារិកសិស្សទៅដល់ភាគីទីបីដោយមិនមានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីមាតាបិតា អាណាព្យាបាលតាមផ្លូវច្បាប់ ឬសិស្សឡើយ។

ដោយហេតុថា U.S. Department of Homeland Security (“DHS”) (ក្រសួងមហាផ្ទៃសហរដ្ឋអាមេរិក) និងបុព្វាធិការីបានបញ្ជាក់ជាគោលការន៍ទូទៅថា ក្នុងនាមជាមន្ត្រីអនុវត្តច្បាប់អន្តោប្រវេសន៍សហព័ន្ធត្រូវតែទទួលការយល់ព្រមជាមុនពីមន្ត្រី DHS ជាន់ខ្ពស់សិនមុននឹងចាត់វិធានការផ្លូវច្បាប់ណាមួយ— ដូចជាការឃាត់ខ្លួន ការសម្ភាសន៍ ការឆែកឆេ ឬការតាមដានមើល — នៅតាម ឬផ្តោតលើសាលារៀន ដែល DHS បានចាត់ទុកថាជា "ទីកន្លែងរសើប"។

ដោយហេតុថា LPS មើលថែរក្សាសិស្សអំឡុងម៉ោងរៀន និងអំឡុងម៉ោងសកម្មភាពក្រៅម៉ោងសិក្សា ហើយវាគឺជាទំនួលខុសត្រូវរបស់ LPS ក្នុងការការពារសិទ្ធិរបស់សិស្សរាល់រូបដែលមានទំនាក់ទំនងនឹងមន្ត្រីអនុវត្តច្បាប់។

ដោយហេតុថា LPS មិនសួរពីស្ថានភាពអន្តោប្រវេសន៍នៅពេលក្រុមគ្រួសារសិស្សមកចុះឈ្មោះកូនចូលរៀនឡើយហើយ

ដោយហេតុថា វត្តមានរបស់មន្ត្រីអនុវត្តច្បាប់អន្តោប្រវេសន៍នៅក្នុងបរិវេណសាលារៀន ឬអំឡុងពេលសកម្មភាពសិក្សានឹងធ្វើឲ្យប៉ះពាល់ដល់បរិស្ថានអប់រំ និងជះឥទ្ធិពលមិនល្អដល់ការចុះឈ្មោះសិស្សនិងវត្តមានសិស្ស។។

អាស្រ័យហេតុនេះ យើងសូម

សម្រេចថា សិស្ស LPS ទាំងអស់មានសិទ្ធិទទួលដូចគ្នាក្នុងការទទួលបានការអប់រំ និងសេវាសាលារៀនពាក់ព័ន្ធដោយឥតបង់ថ្លៃ ហើយថាសិស្ស LPS ទាំងអស់ទទួលបានការប្រព្រឹត្តិស្មើៗគ្នាដោយមិនគិតពីស្ថានភាពអន្តោប្រវេសន៍របស់ពួកគេឡើយ។

RESOLVED ថាបុគ្គលិក LPS នឹងមិនសួរនាំអំពី កត់ត្រា ឬស្នើសុំព័ត៌មានដែលមានបំណងលាតត្រដាងពីស្ថានភាពអន្តោប្រវេសន៍របស់សិស្ស ឬសមាជិកគ្រួសាររបស់សិស្សឡើយ។ ដោយអនុលោមទៅតាមសិទ្ធិអប់រំរបស់គ្រួសារនិងសិទ្ធិឯកជន ("FERPA"), បុគ្គលិក LPS នឹងមិនលាតត្រដាងពីស្ថានភាពអន្តោប្រវេសន៍ ឬព័ត៌មានដែលអាចកំណត់អត្តសញ្ញាណបុគ្គលរបស់សិស្ស ឬសិស្សដែលមានបំណងចូលរៀន ឬសមាជិកគ្រួសារសិស្សណាម្នាក់ដោយមិនមានការយល់ព្រមពីមាតាបិតាសិស្សឡើយ។ បុគ្គលិក LPS នឹងបដិសេធចំពោះការចែករំលែកព័ត៌មានស្ម័គ្រចិត្តទាំងអស់ជាមួយភ្នាក់ងារអន្តោប្រវេសន៍ទូទាំងទិដ្ឋភាពទាំងអស់របស់មណ្ឌលទៅតាមទំហំដែលកំណត់ដោយច្បាប់។

សម្រេចថា មន្ត្រីអនុវត្តច្បាប់អន្តោប្រវេសន៍សហព័ន្ធទាំងអស់ ឬបុគ្គលិកដទៃទៀតដែលចាំជួយដល់មន្ត្រីអនុវត្តច្បាប់អន្តោប្រវេសន៍សហព័ន្ធដែលស្នើសុំចូលក្នុងបរិវេណអគារសាលារៀន Lynn Public School នឹងត្រូវនាំទៅកាន់ទីចាត់ការនៃអគារនោះ ខណៈពេលនោះគេនឹងធ្វើការជូនដំណឹងដល់ប្រធាននាយក។ បន្ទាប់មក ប្រធាននាយកនឹងជូនដំណឹងដល់មេធាវីរបស់ Lynn Public Schools ហើយបន្ទាប់មកបន្តដំណើរការជាបន្ទាន់ចំពោះសាលារៀននោះដើម្បីជួបជាមួយនិងសាកសួររកបណ្ណសម្គាល់ខ្លួនរបស់ភ្នាក់ងារអន្តោប្រវេសន៍នោះ ហេតុផលដែលពួកគេចូលមក និងដីការដែលមានចុះហត្ថលេខាដោយចៅក្រមរដ្ឋ ឬសហព័ន្ធ ឬចៅក្រមថ្នាក់ទាប។ ប្រសិនបើមិនមានដីការដែលមានចុះហត្ថលេខាដោយចៅក្រមរដ្ឋ ឬសហព័ន្ធ ឬចៅក្រមថ្នាក់ទាបទេ នឹងមិនអនុញ្ញាតឲ្យចូលឡើយ។

សម្រេចថា ដីកានិងសំណើដទៃទៀតទាំងអស់ដែលបានទទួលដោយ LPS ដើម្បីទទួលបានព័ត៌មានពីកំណត់ត្រាអប់រំរបស់សិស្សនឹងត្រូវបញ្ជូនទៅកាន់មេធាវីរបស់ LPS ជាបន្ទាន់ដើម្បីកំណត់ការឆ្លើយតបចំពោះដីកានិងសំណើរទាំងនេះ នឹងពិគ្រោះជាមួយប្រធាននាយក ហើយនឹងអនុវត្តឲ្យបានពេញលេញទៅតាមអំណាចផ្លូវច្បាប់របស់ LPS ដើម្បីការពារសិទ្ធិធម្មនុញ្ញនិងសិទ្ធិផ្លូវច្បាប់របស់សិស្ស LPS។

សម្រេចថា នៅក្នុងរយៈពេល ៣ 90 ថ្ងៃ ប្រធាននាយកនឹងបង្កើតផែនការបណ្តុះបណ្តាលគ្រូ មន្ត្រីរដ្ឋបាល និងបុគ្គលិកដទៃទៀតស្តីពីគោលនយោបាយនេះ និងអនុវត្តឲ្យបានប្រសើរបំផុតដើម្បីធានាសុខុមាលភាពរបស់សិស្សដែលអាចទទួលរងផលប៉ះពាល់ដោយអន្តោប្រវេសន៍ដោយការអនុវត្តច្បាប់អន្តោប្រវេសន៍។ ផែនការនេះនឹងត្រូវអនុវត្តនៅក្នុងរយៈពេល៥ខែក្រោយ ហើយនឹងត្រូវធ្វើឡើងវិញដដែលៗជារៀងរាល់ឆ្នាំ។

សម្រេចថា LPS នឹងចែកចាយលិខិតដែលរៀបរាប់សង្ខេបពីខ្លឹមសារនៃការសម្រេចទាំងនេះដល់បុគ្គលិកនិងមាតាបិតាសិស្សជាភាសាដែលគេប្រើជាទូទៅនៅក្នុងទីក្រុងនេះ។ លិខិតនេះនឹងមានបិទផ្សាយនៅក្នុង LPS Parent Information Center (មណ្ឌលព័ត៌មានមាតាបិតា) និងមានជាភាសាផ្សេងៗសម្រាប់មាតាបិតា ឬអាណាព្យាបាលសិស្ស។

សម្រេចថា LPS នឹងផ្សព្វផ្សាយតនៅតាមសាលារៀននីមួយៗ សម្រាប់ឲ្យគ្រួសារសិស្សបានជ្រាប និងចែកចាយដល់សិស្សម្នាក់ៗនូវបញ្ជីធនធានដែលរួមមានអង្គការនានាប្រចាំសហគមន៍ អង្គភាពសេវាផ្លូវច្បាប់ និងព័ត៌មានពាក់ព័ន្ធដទៃទៀត។ នៅពេល និងដែលអាចប្រព្រឹត្តិទៅបាន នឹងមានការបកប្រែឯកសារទាំងនោះផងដែរ។

សម្រេចថា ច្បាប់ចម្លងនៃការសម្រេចទាំងនេះគួរតែផ្ញើទៅកាន់អគ្គមេធាវីរដ្ឋ Massachusetts Attorney និងអ្នកតំណាងផ្លូវច្បាប់សហព័ន្ធ រដ្ឋ និងមូលដ្ឋានរបស់ទីក្រុង Lynn។

**អនុម័តដោយគណៈកម្មការសាលារៀន ថ្ងៃទី 11 ឧសភា 2017**